**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**

លេខ បព ៦៩/២០២៥ កបទ.សអ

សេចក្តីប្រកាសព័ត៌មាន

## បទបង្ហាញស្តីពីការផ្ទុះឡើងនូវការវាយប្រហារដោយអាវុធ នៅតាមបណ្តោយព្រំដែនកម្ពុជា-ថៃ

នៅព្រឹកថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០២៥ លោកជំទាវ អ៊ិត សោភា រដ្ឋលេខាធិការប្រចាំការ នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានដឹកនាំការធ្វើបទបង្ហាញស្តីពីការផ្ទុះឡើងនូវការវាយប្រហារដោយអាវុធនៅតាមបណ្តោយព្រំដែនកម្ពុជា-ថៃ ជូនដល់ប្រធាន និងតំណាងបេសកកម្មការទូតចំនួន៣៣ប្រទេស និងទីភ្នាក់ងារអង្គការអន្តរជាតិនៅទីក្រុងភ្នំពេញ។ ប្រធាននៃស្ថានតំណាងកម្ពុជានៅបរទេស និងសមាជិកក្រុមអ្នកសង្កេតការណ៍អាស៊ានប្រចាំកម្ពុជា ក៏បានចូលរួមស្តាប់បទបង្ហាញនេះ តាមប្រព័ន្ធវីដេអូផងដែរ។

លោកជំទាវរដ្ឋលេខាធិការប្រចាំការ អ៊ិត សោភា បានរំលឹកឡើងវិញនូវការវិវត្តនៃព្រឹត្តិការណ៍ មុនឈានដល់ការបើកការវាយលុករបស់ថៃមកលើកម្ពុជា នៅរសៀលថ្ងៃទី៧ ខែធ្នូ ឆ្នាំ២០២៥ ជាពិសេសការផ្ទុះមីនកាលពីថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២៥ ខណៈដែលកងកម្លាំងថៃនៅតែបន្តសកម្មភាពរំលោភបំពាន ការបាញ់ប្រហារលើជនស៊ីវិលនៅភូមិព្រៃចាន់ ខេត្តបន្ទាយមានជ័យ នៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២៥ និងការលែងទទួលស្គាល់សេចក្តីថ្លែងការណ៍រួមទីក្រុងគូឡាឡាំពួ ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២៥ ដោយប្រទេសថៃ ដោយផ្អែកលើការចោទប្រកាន់មកលើកម្ពុជាអំពីបញ្ហាគ្រាប់មីនថ្មី ដែលគ្មានមូលដ្ឋាន។

លោកជំទាវរដ្ឋលេខាធិការប្រចាំការបានថ្កោលទោសការវាយប្រហាររបស់ថៃដោយប្រើអាវុធធុនធ្ងន់រួមមាន រថក្រោះ កាំភ្លើងធំ កាំភ្លើងត្បាល់ យន្តហោះចម្បាំង និងផ្សែងពុលមកលើទីតាំងកម្ពុជាជាច្រើន ដែលបានបណ្តាលឲ្យមានមនុស្សស្លាប់ និងរងរបួសមួយចំនួន ព្រមទាំងបំផ្លិចបំផ្លាញផ្ទះសម្បែង ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ និងសម្បត្តិបេតិកភណ្ឌជាតិ ដែលត្រូវបានការពារ យ៉ាងដំណំ។ លោកជំទាវ បានច្រានចោលនូវការអះអាងបំភាន់ថា កម្ពុជាបានឈ្លានពានប្រទេសថៃ និងបានផ្តើមការវាយប្រហារ ដោយបានគូសបញ្ជាក់ថា ការវាយលុកថ្មីៗមកលើកម្ពុជា គឺជាការរំលោភយ៉ាងធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិ ធម្មនុញ្ញអង្គការសហប្រជាជាតិ និងអាស៊ាន និងស្មារតីនៃសហគមន៍អាស៊ាន។ លោកជំទាវបានលើកឡើងអំពីការប្រើប្រាស់កម្លាំងពីសំណាក់យោធាថៃ ក្នុងការកំណត់ព្រំដែន ដែលធ្វើឲ្យប៉ះពាល់ដល់ស្ថិរភាព

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល : mfaic@mfaic.gov.kh

សំខាន់ៗនៃការងារបោះបង្គោលព្រំដែនលេខ៥២–៥៩ និង៤២–៤៧ ដែលសម្រេចបានដោយគណៈកម្មការចម្រុះខណ្ឌសីមាព្រំដែនគោកកម្ពុជា-ថៃ។

លោកជំទាវរដ្ឋលេខាធិការប្រចាំការ អ៊ិត សោភា បានគូសបញ្ជាក់ពីការវាយតម្លៃខ្ពស់របស់កម្ពុជាចំពោះវត្តមានរបស់ក្រុមអ្នកសង្កេតការណ៍អន្តរកាល (IOT) និងក្រុមអ្នកសង្កេតការណ៍អាស៊ាន (AOT) ក្នុងការបញ្ជាក់ពីការប្តេជ្ញាចិត្តយ៉ាងស្មោះស្ម័គ្ររបស់កម្ពុជាចំពោះបទឈប់បាញ់ និងសេចក្តីថ្លែងការណ៍រួមទីក្រុងគូឡាឡាំពួ។ លោកជំទាវបានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះប្រទេសជាដៃគូទាំងអស់ដែលបានអំពាវនាវឱ្យមានការអត់ធ្មត់ និងការប្តេជ្ញាចិត្តពេញលេញចំពោះសេចក្តីថ្លែងការណ៍រួមទីក្រុងគូឡាឡាំពួ និងការដោះស្រាយជម្លោះដោយសន្តិវិធី។ លោកជំទាវបានសម្តែងក្តីសង្ឃឹមថា ប្រទេសថៃនឹងធ្វើសកម្មភាពស្របតាមការប្តេជ្ញាចិត្តរបស់ខ្លួនចំពោះសន្តិភាព និងការគោរពច្បាប់អន្តរជាតិ។

ឯកឧត្តមឧត្តមសេនីយ៍ឯក រ៉ាត់ ដារ៉ារ័ត្ន រដ្ឋលេខាធិការក្រសួងការពារជាតិ បានធ្វើបទបង្ហាញអំពីអង្គហេតុនៃការការវាយលុកកាន់តែខ្លាំងរបស់យោធាថៃ នៅតំបន់ជាច្រើនក្នុងខេត្តព្រះវិហារ ឧត្តរមានជ័យ បន្ទាយមានជ័យ បាត់ដំបង និងពោធិ៍សាត់ ព្រមទាំងស្ថានភាពជាក់ស្តែង ដែលកំពុងកើតឡើង។

ថ្ងៃអង្គារ ៤រោច ខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

ភ្នំពេញ ថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០២៥